**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ព្រឹទ្ធសភា**

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំឆ្នាំ២០១៥

*នៅឆ្នាំ២០១៥នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅៈ*

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

*សម្ដេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានចូលមរណភាពនាថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៥ ។ សពរបស់សម្ដេចត្រូវបានតំកល់ទុកធ្វើបុណ្យទក្ខិណានុប្បទានក្នុងរយៈពេល១២ថ្ងៃ ដោយមានការចូលរួមកាន់មរណទុក្ខថ្នាក់ជាតិ និងការគោរពវិញ្ញាណក្ខន្ធពីគ្រប់មជ្ឈដ្ឋាន ទាំងជាតិ និងអន្តរជាតិ។ ពិធីបូជាសពបានប្រព្រឹត្តទៅដោយអធិកអធម ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃ **ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង**សម្ដេចព្រះមហាក្សត្រីយ៍ ព្រះវររាជមាតាជាតិខ្មែរ** ជាទីសក្ការៈ ដោយមានប្រជាពលរដ្ឋរាជធានីភ្នំពេញជាច្រើនម៉ឺននាក់ បានចូលរួមផ្ដល់កិត្តិយសជាចុងក្រោយផង ។*

**១.១ សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា បានៈ**

*-ទទួលភារកិច្ចជាប្រមុខរដ្ឋស្ដីទីចំនួន០៤លើក*

*-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៩លើក ប្រជុំវិសាមញ្ញចំនួន០៥លើក និងប្រជុំពេញអង្គចំនួន០៣លើក*

*-អញ្ជើញចូលរួមក្នុងពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៦២ នៃទិវាបុណ្យ ឯករាជ្យជាតិ៩ វិច្ឆិកា និងពិធីពន្លត់ទៀនជ័យ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាព្រះបាទសម្ដេច ព្រះបរមនាថ នរោត្ដមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជា*



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្ដម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ណាចក្រកម្ពុជា

-អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីសម្ពោធអាគារមជ្ឈមណ្ឌលព្យាបាលមនុស្សចាស់ "អគារព្រះសីហនុរាជ" នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

-អញ្ជើញចូលរួមព្រះរាជពិធីបុណ្យខួបគម្រប់៣ឆ្នាំ នៃការយាងចូលព្រះទីវង្គត **ព្រះករុណា ព្រះបរមរតនកោដ្ឋ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅព្រះធម្មសាលាក្នុងបរិវេណព្រះឧបោសថរតនារាម ព្រះកែវមរកត

-អញ្ជើញចូលរួមព្រះរាជពិធីរាប់បាត្រ ឧទ្ទិសថ្វាយ ព្រះករុណា **ព្រះបរមរតនកោដ្ឋ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅព្រះធម្មសាលា ក្នុងបរិវេណព្រះឧបោសថរតនារាម ព្រះកែវមរកត

-អញ្ជើញជូនព្រះរាជដំណើរព្រះករុណា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត យាងទៅពិនិត្យព្រះរាជសុខភាព នៅសាធារណរដ្ឋប្រជាមានិតចិន

-អញ្ជើញចូលរួមជូន និងទទួលព្រះរាជដំណើរ **ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គស្តេចយាងបំពេញព្រះរាជទស្សនកិច្ច នៅសាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋបារាំង និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

-ដឹកនាំគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញបំពេញទស្សនកិច្ចផ្លូវការ និងមិត្តភាព នៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-អនុញ្ញាតឲ្យឯកឧត្តម Mohammad Hamid Ansari អនុប្រធានាធិបតីនៃសាធារណរដ្ឋឥណ្ឌា ចូលជួបសម្តែងការគួរសម និងធ្វើសវនាការក្នុងឱកាសដែលឯកឧត្តមដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃសាធារណរដ្ឋឥណ្ឌា មកបំពេញទស្សនកិច្ចជាផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា

-អនុញ្ញាតឲ្យឯកឧត្តម Laszlo KOVERប្រធានរដ្ឋសភាប្រទេសហុងគ្រី និងគណៈប្រតិភូចូលជួបសម្តែងការគួរសម និងធ្វើសវនាកា

-អនុញ្ញាតឲ្យឯកឧត្តមArkenImirbaki អនុប្រធានសភាប្រជាជនចិនតំណាងទូទាំងប្រទេស និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម និងធ្វើសវនាការ

-អនុញ្ញាតឲ្យឯកឧត្តម Han Qide អនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម និងធ្វើសវនាការ

-អនុញ្ញាតឲ្យឯកឧត្តម Mian Rabbani ប្រធានព្រឹទ្ធសភា នៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម និងធ្វើសវនាការ

-អនុញ្ញាតឲ្យឯកឧត្តម Thomas GAMBKE ប្រធានក្រុមសមាជិកសភាអាល្លឺម៉ង់ ចូលជួបសម្តែងការគួរសម និងធ្វើសវនាការ

-អនុញ្ញាតឲ្យឯកឧត្តម TRAN VAN HANG ប្រធានគណៈកម្មការកិច្ចការបរទេស នៃរដ្ឋសភាវៀតណាម និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម

-អនុញ្ញាតឲ្យឯកឧត្តម TRAN DUC LUONG អគ្គរង់អធិការកិច្ចរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម

-ទទួលសារតាំងពីឯកឧត្តម Naveen Srivasiava ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋឥណ្ឌា ប្រចាំព្រះរាជាណាចក្រកម្ពុជា

-ទទួលសារតាំងពីឯកឧត្តម Aziz Ponary MI ima ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋឯកភាពតង់ហ្សានី ប្រចាំព្រះរាជាណាចក្រកម្ពុជា

-ទទួលសារតាំងពីឯកឧត្តម George EDGAR ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃស្ថានប្រតិភូសហភាពអឺរ៉ុប ប្រចាំព្រះរាជាណាចក្រកម្ពុជា

-ទទួលសារតាំង ពីឯកឧត្តម William A.Heidt ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសហរដ្ឋអាមេរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា

-អនុញ្ញាតឲ្យឯកឧត្តម Dherar Naser al-tuwaijri ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋគុយវ៉ែត ចូលជួបសម្តែងការគួរសម និងធ្វើសវនាការ

-អនុញ្ញាតឲ្យឯកឧត្តម Dinesh K.Patnaik ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថ

ភាពនៃសាធារណរដ្ឋឥណ្ឌា ដែលបានបញ្ចប់បេសកកម្មការទូត នៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជំរាបលា

-អនុញ្ញាតឲ្យឯកឧត្តម Christopher B.Montero ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋហ្វីលីពីន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលតែងតាំងថ្មី ចូលជួបសម្តែងការគួរសម

-អនុញ្ញាតឲ្យឯកឧត្តម Nuttavudh Photisaro ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រថៃ ចូលជួបសម្តែងការគួរសម

-អញ្ជើញចូលរួមពិធីបុណ្យគម្រប់ខួប១០០ថ្ងៃ និងដង្ហែអដ្ឋិធាតុសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ពោះទៅភូមិកន្ទែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង

-អញ្ជើញប្រារព្ធពិធីបង្សុកូល ឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខ័ន្ធបុព្វការីជន យុទ្ធជន យុទ្ធនារី ដែលបានពលីជីវិតក្នុងសម័យតស៊ូរំដោះជាតិមាតុភូមិ នាចេតិយ៍ពាមអំពិល នៅភូមិកន្ទែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង

-បានណែនាំ និងឧបត្ថម្ភដល់ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត របស់សម្តេចឲ្យចុះពិនិត្យព្យាបាលជំងឺដោយឥតគិតថ្លៃ ជូនប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ និងនៅខេត្តកំពង់ឆ្នាំង

-អញ្ជើញចុះមូលដ្ឋាន និងចូលរួមកម្មវិធីផ្សេងៗចំនួន៣២លើក

-បានចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន១១៣ ព្រះរាជក្រឹត្យ និងលិខិតសុំប្រទានសិទ្ធិពីព្រះមហាក្សត្រចំនួន១១៣លិខិត

-ទទួលសំណើពីរដ្ឋាភិបាលចំនួន១០៨ច្បាប់ ពីរដ្ឋសភាចំនួន០៥ច្បាប់

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៦៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៥៨៩ច្បាប់ ។

**១.២.ឯកឧត្តម នែ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា បាន :**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០៥លើក

-អញ្ជើញចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន១៦លើក ប្រជុំវិសាមញ្ញចំនួន០២លើក និងប្រជុំពេញអង្គចំនួន០២លើក

-អញ្ជើញចូលរួមក្នុងពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៦២ នៃទិវាបុណ្យឯករាជ្យ

ជាតិ៩ វិច្ឆិកា និងពិធីពន្លត់ទៀនជ័យ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីសម្ពោធអគារមជ្ឈមណ្ឌលព្យាបាលមនុស្សចាស់ **"អគារព្រះសីហនុរាជ"** នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

-អញ្ជើញជូន និងទទួលដំណើរគណៈប្រតិភូនៃសាធារណរដ្ឋប្រជាមានិតឡាវ អញ្ជើញមកចូលរួមគោរពវិញ្ញាណក្ខន្ធសព**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា

-អញ្ជើញចូលរួមពិធីបុណ្យគម្រប់ខួប១០០ថ្ងៃ និងដង្ហែអដ្ឋិធាតុសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ឆ្ពោះទៅភូមិកន្ទៃងជ្រៅ ឃុំក្រពៅ ស្រុកកំចាយមារ ខេត្តព្រៃវែង

-អញ្ជើញចូលរួមជូន និងទទួលដំណើរ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** អញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-អនុញ្ញាតឲ្យឯកឧត្តម **ផាន់ យុនហឺ (Pan Yunhe)** ប្រធានគណៈកម្មាធិការកិច្ចការបរទេស នៃសភាប្រឹក្សានយោបាយប្រជាជនចិន ចូលជួបសម្តែងការគួរសម

-អញ្ជើញជាអធិបតីថ្ងៃសុន្ទរកថាបើកវេទិកាថ្នាក់ខេត្ត ស្តីពីការចូលរួមលើកកម្ពស់សមត្ថភាពក្រុមប្រឹក្សាឃុំ-សង្កាត់ និងអភិបាលកិច្ចក្នុងការអភិវឌ្ឍមូលដ្ឋាន

-អញ្ជើញចូលរួមក្នុងពិធីបើកមហាសន្និបាត (APA) លើកទី៨ របស់សភាតំបន់អាស៊ី ក្រោមប្រធានបទ " ការជម្រុញ សន្តិភាព ការផ្សះផ្សា និងការសន្ទនា ក្នុងតំបន់អាស៊ី"

-អញ្ជើញចុះមូលដ្ឋាន និងចូលរួមកម្មវិធីផ្សេងៗចំនួន២១លើក

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១១០ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៣៣ច្បាប់ ។

**១.៣ ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បានៈ**

-អញ្ជើញចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន២៤លើក ប្រជុំវិសាមញ្ញចំនួន០៨លើក និងប្រជុំពេញអង្គចំនួន០៥លើក

-អញ្ជើញចូលរួមក្នុងពិធីបុណ្យកឋិនដែលផ្តួចផ្តើមដោយ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដង្ហែទៅកាន់វត្តឧត្តមសាមគ្គីរតនារាម ស្ថិតក្នុងភូមិហ្វាំង ឃុំបានប៉ុង ស្រុកវើនសៃ ខេត្តរតនគិរី

-អញ្ជើញចូលរួមក្នុងពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៦២ នៃទិវាបុណ្យ ឯករាជ្យជាតិ៩ វិច្ឆិកា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

-អញ្ជើញចូលរួមជូនដំណើរ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធាន ព្រឹទ្ធសភា** អញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-អញ្ជើញចូលរួមពិធីបុណ្យគម្រប់ខួប១០០ថ្ងៃ និងដង្ហែអដ្ឋិធាតុសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ឆ្ពោះទៅភូមិកន្ទែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង

-អញ្ជើញចូលរួមប្រជុំការងារសមាគមមិត្តភាពកម្ពុជា-ចិន

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ទៅបំពេញទស្សនកិច្ចជាផ្លូវការ នៅសាធារណរដ្ឋប្រជាមានិតចិន

-អនុញ្ញាតឲ្យភ្ញៀវជាតិ និងអន្តរជាតិចូលជួបសម្តែងការគួរសម និងពិភាក្សាការងារចំនួន០៧លើក

-អញ្ជើញជាអធិបតីថ្ងៃសុន្ទរកថាបើកសិក្ខាសាលាស្តីពី **"ការចូលរួមរបស់ប្រព័ន្ធផ្សព្វផ្សាយក្នុងដំណើរការប្រជាធិបតេយ្យ"**

-អញ្ជើញជាអធិបតីក្នុងពិធីថ្ងៃសុន្ទរកថាបិទ-បើក និងចូលរួមវេទិកាភូមិភាគ៣ នៅខេត្តកណ្តាល ភូមិភាគ៧ នៅខេត្តពោធិ៍សាត់ ភូមិភាគ៤ នៅខេត្តសៀមរាប សរុបចំនួន០៤លើក

-អញ្ជើញជួបសំណេះសំណាល ចែកអំណោយដល់អាណាព្យាបាល និងកុមារក្រីក្រ លោកគ្រូ អ្នកគ្រូ និងពិនិត្យការងារនៅតាមមូលដ្ឋាននានាចំនួន០៤លើក

-អញ្ជើញជួបសំណេះសំណាល និងនាំសមាគមគ្រូពេទ្យស្ម័គ្រចិត្តមកពីប្រទេសបារាំងទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋក្រីក្រ ដោយឥតគិតថ្លៃ នៅក្នុងខេត្តកណ្តាល និងខេត្តត្បូងឃ្មុំ ចំនួន០២លើក

-អញ្ជើញជាអធិបតី និងជាកិត្តិយសក្នុងអង្គសិក្ខាសាលា សន្និសីទ សន្និបាត និងពិធីផ្លូវការផ្សេងៗចំនួន២៣លើក

-អញ្ជើញនាំយកទៀនព្រះវស្សា និងចូលរួមក្នុងពិធីកាន់បិណ្ឌ នៅវត្តចំនួន០២ក្នុងឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវចំនួន០២លើក

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩៨២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៣៥៨ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំពេញអង្គព្រឹទ្ធសភា**

-បានប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន២៣លើក ប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០៥លើក និងប្រជុំវិសាមញ្ញចំនួន០៨លើក និងបានពិនិត្យ ឲ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន១៣ និងសេចក្តីស្នើច្បាប់ចំនួន០៧ ដែលព្រឹទ្ធសភាទទួលបានពីរដ្ឋសភា ។

**៣.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា**

-ក្នុងឆ្នាំ២០១៥នេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម ៖

**៣.១ មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល និងតំណាងក្រុមតំណាងរាស្ត្រហត្ថលេខីរបស់រដ្ឋសភា ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន១៣ និងសេចក្តីស្នើច្បាប់ចំនួនចំនួន០៧

-គណៈកម្មការពិសេស ប្រជុំពិនិត្យសិក្សា និងរៀបចំសេចក្តីស្នើវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា និងសេចក្តីស្នើវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងពិនិត្យសម្រេចលើសេចក្តីព្រាងសេចក្តីស្នើវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា និងឯកសារពាក់ព័ន្ធ

-ក្រុមសមាជិកព្រឹទ្ធសភាហត្ថលេខី ប្រជុំជាមួយគណៈកម្មការទី៦ នៃរដ្ឋសភា ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មមាត្រា២១ នៃច្បាប់លក្ខន្តិកៈសមាជិកព្រឹទ្ធសភា

-ប្រជុំពិនិត្យ និងឆ្លងឯកសារស្តីពី " សេចក្តីកំណត់ និងនីតិវិធីអនុវត្តចំពោះប្រការទាំងឡាយនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ "

-ប្រជុំពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រាងបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត និងការរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦

-ប្រជុំផ្សព្វផ្សាយច្បាប់ ស្តីពីការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-ប្រជុំរួមយោបល់លើសេចក្តីព្រាងនៃការសិក្សាបឋមអំពីការងារនីតិកម្ម ការធ្វើវិសោធនកម្ម គម្រោងធ្វើវិសោធនកម្មច្បាប់ជាធរមាន និងគម្រោងតាក់តែងច្បាប់ថ្មី ។

**៣.២ មុខងារតំណាង**

-រៀបចំវេទិកាថ្នាក់ខេត្ត និងថ្នាក់ស្រុកចំនួន០៨លើក ស្តីពីការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំក្នុងការអភិវឌ្ឍមូលដ្ឋានដោយធានាសមភាពយេនឌ័រ នៅខេត្តកណ្តាល, លើកកម្ពស់សមត្ថភាព និងពង្រឹងអភិបាលកិច្ចក្នុងកិច្ចអភិវឌ្ឍមូលដ្ឋាន នៅខេត្តសៀមរាប និងខេត្តតាកែវ, គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពនិងការលើកកម្ពស់សេវាសាធារណៈ នៅខេត្តពោធិ៍សាត់, ការចូលរួមអនុវត្តកាត់បន្ថយភាពក្រីក្រនៅថ្នាក់មូលដ្ឋាន នៅខេត្តព្រៃវែង, និងវេទិកាស្តីពីការបង្កើនសមត្ថភាព និងការអភិវឌ្ឍមូលដ្ឋានរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តមណ្ឌលគិរី និងខេត្តកំពង់ធំ ។

-ទទួលពាក្យបណ្តឹងចំនួន១១១ករណី បញ្ជូនទៅក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយបានចំនួន១០៨ករណី បានទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងបានចំនួន១៩ករណី ទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធបានចំនួន១២១ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងបានចំនួន០៤ករណី កំពុងពិនិត្យសិក្សាចំនួន១៥ករណី និងតំកល់ទុកមិនចាត់ការចំនួន០៩ករណី ។

-សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេស ចំនួន១៥៨៧លើក ដើម្បីសំណេះសំណាល ជួបពិភាក្សា សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ព្យាបាលជំងឺ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ នៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន ផ្សព្វផ្សាយព័ត៌មាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងកិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗសរុបចំនួន២៧២លើក ។

**៣.៣ មុខងារត្រួតពិនិត្យ**

-ជួបសវនាការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងបរិស្ថាន ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ ក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងទេសចរណ៍ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីតាមដានការអនុវត្តការងាររបស់ក្រសួងពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ។

**៣.៤ មុខងារព័ត៌មាន**

-អញ្ជើញចុះសិក្សាស្រាវជ្រាវប្រមូលព័ត៌មាន ផ្សព្វផ្សាយព័ត៌មាន តាមដានការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យ សុខាភិបាល អប់រំ សិទ្ធិមនុស្ស ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ ថាមពលអគ្គិសនី ទេសចរណ៍ កសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម តុលាការ សិទ្ធិមនុស្ស ការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ នៅថ្នាក់ក្រោមជាតិ និងបញ្ហាប្រឈមនានា នៅខេត្តស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ កំពង់ឆ្នាំង សៀមរាប មណ្ឌលគិរី កំពង់ធំ ក្រចេះ កោះកុង កំពង់ស្ពឺ កំពត ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន និងខេត្តព្រះសីហនុ ។

**៤.កិច្ចសហប្រតិបត្តិការអន្តរជាតិ**

-ថ្នាក់ដឹកនាំ សមាជិក-សមាជិកាគណៈកម្មការនានា របស់ព្រឹទ្ធសភា បានអញ្ជើញទៅបំពេញទស្សនកិច្ចចំនួន៣២លើក ដើម្បីចូលរួមកិច្ចប្រជុំ សន្និបាត សន្និសីទ សិក្ខាសាលា វេទិកា និងពិធីផ្សេងៗ នៅសាធារណរដ្ឋកូរ៉េ សាធារណរដ្ឋសង្គមនិយមវៀតណាម

សាធារណរដ្ឋប្រជាមានិតចិន ព្រះរាជាណាចក្រថៃ ប្រទេសហ្វីលីពីន ប្រទេសស៊ុយអែត ប្រទេសហ្វាំងឡង់ ប្រទេសម៉ាឡេស៊ី ប្រទេសឥណ្ឌូនេស៊ី ប្រទេសតួកគី ប្រទេសអេក្វាដ័រ ប្រទេសស្វីស ប្រទេសអង់គ្លេស ប្រទេសប៊ែលហ្សិក ប្រទេសអ៊ីរ៉ង់ ប្រទេសនូវែលសេឡង់ និងនៅសាធារណរដ្ឋបារាំង ។

រាជធានីភ្នំពេញ, ថ្ងៃទី[illegible] ខែមករា ឆ្នាំ២០១៦

ជ. ប្រធានព្រឹទ្ធសភា

អនុប្រធានទី២

**ទេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ